រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

002KH01A-01

អត្ថបទសិក្សា ទី ៤

"ដំណឹងល្អបំផុត"



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រួគង្វាល

២

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ពិធីជ្រមុជទឹកតំណាងការស្លាប់ និងការកប់ទៅក្នុងផ្នូររបស់យើងជាមួយព្រះគ្រីស្ត

ទេវទូតរបស់ព្រះអម្ចាស់ពោលមកកាន់លោកភីលីពថា÷ *«សូមក្រោកឡើងធ្វើដំណើរតាមផ្លូវចុះពីក្រុងយេរូសាឡឹម ទៅក្រុងកាសាជាផ្លូវស្ងាត់នោះទៅ »* ។ លោកភីលីពក៏ក្រោកឡើងចេញដំណើរទៅ ។ នៅតាមផ្លូវមានជនជាតិអេត្យូពីមួយរូប ជាមនុស្សកម្រៀវលោកជាមន្ត្រីជាន់ខ្ពស់របស់មហាក្សត្រីយានីកន់ដាស ដែលគ្រងរាជ្យនៅស្រុកអេត្យូពី ហើយលោកជាអ្នកកាន់កាប់ព្រះរាជទ្រព្យទាំងប៉ុន្មាន ។ លោកបានមកថ្វាយបង្គំព្រះជាម្ចាស់នៅក្រុងយេរូសាឡឹម ហើយធ្វើដំណើរវិលត្រឡប់ទៅវិញ ដោយជិះរទេះសេះទាំងអានគម្ពីរព្យាការីអេសាយផង ។

ព្រះវិញ្ញាណមានព្រះបន្ទូលមកលោកភីលីពថា÷ *«ចូរទៅមុខ រួចចូលទៅជិតរទេះសេះនោះទៅ »* ។ លោកភីលីពក៏រត់ទៅមុខ ហើយឮមន្ត្រីអេធីព្យូពីអានគម្ពីរព្យាការីអេសាយ លោកភីលីពសួរមន្ត្រីនោះថា÷ «តើលោកយល់សេចក្តី ដែលលោកកំពុងតែអាននេះឬទេ ? »។

លោកមន្ត្រីតបមកវិញថា÷ «ធ្វើម្តេចអោយខ្ញុំយល់បាន បើគ្មាននរណាពន្យល់ណែនាំសោះនោះ ! » ។

ខ សំរាប់ទន្ទេញ

«ទីនេះមានទឹក តើមានអ្វីឃាត់ខ្ញុំ មិនឱ្យទទួលពិធីជ្រមុជទឹក !» ។
(កិច្ចការ ៨:៣៦)

កិច្ចការដែលត្រូវអនុវត្ត

- ពន្យល់ន័យអំពីពិធីជ្រមុជទឹកប្រាប់គ្រួសាររបស់អ្នក ។ (ពិធីជ្រមុជទឹកជាទីសំគាល់ថា ព្រះជាម្ចាស់លើកលែងទោសអំពើបាបអោយយើង ហើយយើងក៏បានរួមជាមួយព្រះគ្រីស្តដោយស្លាប់ខាងជីវិតពេញដោយអំពើបាប និងរស់ឡើងវិញដើម្បីចាប់ផ្តើមជីវិតថ្មី ជីវិតបរិសុទ្ធ និងជីវិតអស់កល្បដោយសារព្រះអង្គដែរ) ។
- និទានរឿងអំពីលោកភីលីព និង មន្ត្រីជាតិអេត្យូពី ប្រាប់គ្រួសាររបស់អ្នក ។

បានសិក្សាអត្ថបទនេះ និងបានធ្វើកិច្ចការដែលត្រូវអនុវត្តរួចហើយ

_____ _____

(ថ្ងៃ ខែ) (ហត្ថលេខារបស់គ្រូបង្ហាត់)

© Project WorldReach © SEAN

កូឡុស ២:១២ ចែងថា÷ «*ពេលបងប្អូនទទួលពិធីជ្រមុជទឹក បងប្អូនត្រូវកប់ក្នុងផ្នូររួមជាមួយព្រះគ្រីស្ត ហើយដោយបងប្អូនរួមក្នុងអង្គព្រះគ្រីស្ត បងប្អូនក៏មានជីវិតរស់ឡើងវិញ រួមជាមួយព្រះអង្គដែរ ព្រោះបងប្អូនមានជំនឿលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ដែលបានប្រោសព្រះគ្រីស្តអោយមានព្រះជន្មរស់ឡើងវិញ* » ។

ពិធីជ្រមុជទឹកមានពីរផ្នែក : ផ្នែកមើលឃើញដែលទាក់ទងនឹងរូបកាយ (ទឹក) និងផ្នែកខាងព្រលឹងវិញ្ញាណ (កិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ) ។ ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ធ្វើអោយយើងបានរួមជាមួយព្រះគ្រីស្ត ដោយសារជំនឿរបស់យើង ។

តើអ្នកណាដែលធ្វើអោយយើងបានរួមជាមួយព្រះយេស៊ូ ?
ព្រះ _____ ដ៏វិសុទ្ធ ។

តើអ្នកចង់អោយព្រះអង្គអត់ទោសអោយអ្នក ហើយអោយព្រះអង្គប្រទានជីវិតថ្មីដល់អ្នកដែរឬទេ ?

☐ ចង់ ។

☐ មិនចង់ទេ ។

លោកក៏អញ្ជើញលោកភីលីពឡើងជិះរទេះសេះជាមួយ ។ រីឯអត្ថបទគម្ពីរ ដែលលោកកំពុងអាននោះ គឺ" *លោកត្រូវគេនាំយកទៅដូចជាចៀម ដែលគេនាំទៅសម្លាប់ លោកពុំបានហើបមាត់ទាល់តែសោះ គឺប្រៀបដូចជាកូនចៀម ដែលស្ងៀមស្ងាត់នៅមុខអ្នកកាត់រោម ។*

លោកត្រូវគេបន្ទាបបន្ថោក ហើយគេមិនរកយុត្តិធម៌ជូនលោកឡើយ ។ គ្មាននរណាអាចតំណាលអំពីពូជពង្សរបស់លោកបានទេ ព្រោះគេបានដកជីវិតរបស់លោកចេញពីផែនដីនេះបាត់ទៅហើយ" ។ មន្ត្រីនោះសួរលោកភីលីពថា÷ «*សូមប្រាប់ខ្ញុំផង តើព្យាការីមានប្រសាសន៍ដូច្នេះ សំដៅលើអ្នកណា ? តើលោកមានប្រសាសន៍អំពីខ្លួនលោកផ្ទាល់ ឬមានប្រសាសន៍អំពីអ្នកណាម្នាក់ផ្សេងៗទៀត ?* » ។

លោកភីលីពក៏ជំរាបជូនដំណឹងល្អ អំពីព្រះយេស៊ូប្រាប់លោកដោយចាប់ផ្តើមពីអត្ថបទគម្ពីរនោះទៅ ។ លោកទាំងពីរចេះតែបន្តដំណើរទៅមុខ ។ លុះដល់កន្លែងមួយមានទឹក លោកមន្ត្រីមានប្រសាសន៍ថា÷ «ទីនេះមានទឹក តើមានអ្វីឃាត់ខ្ញុំមិនអោយទទួលពិធីជ្រមុជទឹក ! » ។

លោកបញ្ជាអោយគេបញ្ឈប់រទេះសេះ ។ លោកមន្ត្រី និងលោក ភីលីពចុះទៅក្នុងទឹកទាំងពីរនាក់ ហើយលោកភីលីពក៏ជ្រមុជទឹក ជូនមន្ត្រីនោះ ។ (កិច្ចការ ៨:២៧-៣៨) ។

នៅក្នុងវគ្គព្រះគម្ពីរ ដែលមន្ត្រីជាតិអេត្យូពីបានអាននេះ តើអ្នក ណាដែលត្រូវគេនាំយកទៅ ដូចជាចៀម ដែលគេនាំទៅសម្លាប់ ?

តើអ្នកណានាំអោយមន្ត្រីជាតិអេត្យូពីនោះជឿជាក់ថា ព្រះយេស៊ូជា ព្រះសង្គ្រោះ ?

តើមន្ត្រីជាតិអេត្យូពីនោះបង្ហាញថា គាត់ពិតជាជឿ ដោយរបៀប ណា ?

ពិធីជ្រមុជទឹកមានន័យថា យើងបានរួមជាមួយព្រះគ្រីស្ត ក្នុងការ សុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ ។ យើង ស្លាប់ លែងមានជីវិតពេញដោយអំពើបាប ហើយចាប់ផ្តើមជីវិត ថ្មី ដែលបរិសុទ្ធ និង អស់កល្ប ។

តើអ្នកណាដែលផ្តល់ជីវិតដូចនេះដល់យើង ? _____

ពិធីជ្រមុជទឹកតំណាងការជំរះសំអាតយើងពីអំពើបាប ។ តែទឹក មិនអាចជំរះអំពើបាបបានទេ ។ ១ យ៉ូហាន ១:៧ ចែងថា៖ *«លោហិតរបស់ព្រះយេស៊ូ ជាព្រះបុត្រារបស់ព្រះអង្គ ជំរះយើងឱ្យ បានបរិសុទ្ធ រួចពីគ្រប់អំពើបាបទាំងអស់ »* ។

តើអ្វីដែលអាចជំរះសំអាតអំពើបាបរបស់យើងបាន ?

ហេតុអ្វីបានជាពេលដែលយើងបានជឿលើព្រះគ្រីស្តហើយ ព្រះ-ជាម្ចាស់មិនអោយយើងធ្លាក់ទៅស្ថាននរក ?

© Project WorldReach © SEAN